ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ ០៧៥៧ ព.ណ.ក.ស.ប

ភ្នំពេញ, ថ្ងៃទី ១៣ ខែ មិនា ឆ្នាំ ២០១៥

**<u>ជម្រាបមក</u>**

**លោកនាយកក្រុមហ៊ុន អេ.អិម.វ៉ាយ អ៊ិនធើណេសិនណាល ត្រេដ ខូ អិលធីឌី**

**កម្មវត្ថុ:** ការកត់ត្រាទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកបារីម៉ាក 真龍 Zhenlong ក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **អេ.អិម.វ៉ាយ អ៊ិនធើណេសិនណាល ត្រេដ ខូ អិលធីឌី** ។

**យោង:**
- មាត្រា ៣ និងមាត្រា ១១ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- លិខិតរបស់ក្រុមហ៊ុន **អេ.អិម.វ៉ាយ អ៊ិនធើណេសិនណាល ត្រេដ ខូ អិលធីឌី** ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៤
- លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន CHINA TOBACCO GUANGXI INDUSTRIAL CO., LTD ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៤
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក 真龍 Zhenlong លេខចុះបញ្ជី KH/៥២៩២៦/១៤ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៤ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកនាយកថា ក្រសួងពាណិជ្ជកម្ម ឯកភាពកត់ត្រាទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកបារីម៉ាក 真龍 Zhenlong ក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **អេ.អិម.វ៉ាយ អ៊ិនធើណេសិនណាល ត្រេដ ខូ អិលធីឌី** ដែលទទួលបានពីក្រុមហ៊ុន CHINA TOBACCO GUANGXI INDUSTRIAL CO., LTD ដូចមានចែងក្នុងលិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ម្ចាស់ម៉ាក ដែលក្រសួងបានតម្កល់ទុករួចហើយ ។

លិខិតទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកនេះ មានសុពលភាព ២(ពីរ) ឆ្នាំ ដោយគិតចាប់ពីក្រោយថ្ងៃចុះហត្ថលេខាចំនួន ៩០(កៅសិប) ថ្ងៃ ហើយអាចនឹងត្រូវបាត់បង់សុពលភាពជាស្វ័យប្រវត្តិវិញ មុនកាលបរិច្ឆេទផុតកំណត់ខាងលើ ប្រសិនបើមានការជូនដំណឹងអំពីការបញ្ចប់សិទ្ធិពីក្រុមហ៊ុន CHINA TOBACCO GUANGXI INDUSTRIAL CO., LTD ដែលជាម្ចាស់ម៉ាក 真龍 Zhenlong នេះ ។

នីតិបុគ្គលដែលទទួលបានសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកនៃផលិតផលម៉ាក 真龍 Zhenlong នេះ ត្រូវបោះពុម្ពផ្សាយលិខិតទទួលស្គាល់នេះក្នុងទំព័រខាងមុខរបស់សារព័ត៌មានល្បីៗភ្លាមយ៉ាងតិចចំនួន ៣(បី) លេខជាប់ៗគ្នា និងត្រូវអនុវត្តឲ្យបានត្រឹមត្រូវនូវលិខិតបទដ្ឋានច្បាប់ និងសារាចរណែនាំរបស់រាជរដ្ឋាភិបាលទាក់ទងនឹងការគ្រប់គ្រងសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ។

អាស្រ័យហេតុនេះ សូមលោកនាយកក្រុមហ៊ុន ជ្រាបជាព័ត៌មាន ។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

រដ្ឋលេខាធិការ

ក្រសួងពាណិជ្ជកម្ម

**អ៊ុក-ប្រជា**

<u>ចម្លងជូន:</u>
- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ **គាត ឈន់**
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានកាំកុងត្រូល
- អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា
- អគ្គនាយកដ្ឋានពន្ធដារ
- ឯកសារ - កាលប្បវត្តិ